# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
លេខ ៣៧/០៣.តក

## ប្រធានតុលាការកំពូល

**<u>ជម្រាបមក</u>**

**លោកប្រធានតុលាការក្រុងភ្នំពេញ**

**<u>*កម្មវត្ថុ:*</u>** អំពីការដោះស្រាយបណ្តឹងជិតចិត្ត ចំពោះអនុប្រធាន និងចៅក្រមតុលាការ ក្រុងភ្នំពេញ ។

កន្លងមកតុលាការកំពូល បានទទួលនូវបណ្តឹងជិតចិត្តជាច្រើន ពីចៅក្រម នៃតុលាការ ក្រុងភ្នំពេញ ដែលតាមមាត្រា ៣៤ ច្បាប់ស្តីពី នីតិវិធីជំនុំជម្រះផ្នែកព្រហ្មទណ្ឌ បណ្តឹងនេះលោកជាប្រធានតុលាការជាអ្នកសម្រេច ។ ប៉ុន្តែតុលាការកំពូលសង្កេតឃើញថាក្នុងការសម្រេចពីបណ្តឹងនេះ លោកពុំទាន់អនុវត្តបានល្អតាមគោលការណ៍ច្បាប់ទេ ។ ជាគោលការណ៍បើមានបណ្តឹងជិតចិត្តលើចៅក្រមណាម្នាក់ គប្បីលោកប្រធានរួសរាន់ដោះស្រាយឱ្យបានឆាប់ដែលអាចធ្វើទៅបាន ។

-ការសម្រេចអំពីបណ្តឹងជិតចិត្ត មិនមែនផ្អែកតែលើឆន្ទៈឬយោបល់ទាំងស្រុងរបស់ចៅក្រម ដែលត្រូវគេប្តឹងនោះទេ គឺត្រូវផ្អែកជាសំខាន់លើមូលហេតុ និងភស្តុតាងរបស់ម្ចាស់បណ្តឹង ដើម្បីសម្រេចថា ត្រូវឱ្យផ្លាស់ប្តូរចៅក្រមកាន់សំណុំរឿងចេញ ឬមិនផ្លាស់ប្តូរ ។

-ក្រោយពេលសម្រេចអំពីបណ្តឹងជិតចិត្តនេះហើយ ត្រូវជូនដំណឹងដល់សាមីម្ចាស់បណ្តឹង ដើម្បីឱ្យគេដឹងថាតើបណ្តឹងរបស់គេត្រូវបានទទួល ឬបដិសេធ ក្នុងករណីបដិសេធ ត្រូវផ្តល់នូវសំអាងហេតុ ។

-មិនគប្បីបិតនៅក្នុងសភាពស្ងាត់ស្ងៀម ដោយមិនឱ្យដំណឹងអ្វីទាំងអស់ដល់ម្ចាស់បណ្តឹងឡើយ ។

សូមលោកប្រធានទទួលនូវការរាប់អានអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣

**ឌិត មុន្ទី**

<u>ចម្លងជូន</u>
-គ្រប់តុលាការខេត្ត-ក្រុង
-ទុកផ្សព្វផ្សាយពេលប្រជុំ
-ឯកសារ